【ចំណុចសំខាន់ៗនៃជំនួយរបស់ជប៉ុនសម្រាប់កំណែទម្រង់ការបោះឆ្នោត】

(1) ក្នុងអំឡុងកិច្ចប្រជុំកំពូលទ្វេភាគីក្នុងខែវិច្ឆិកាឆ្នាំ 2013 សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែនបានធ្វើសំណើទៅកាន់លោកនាយករដ្ឋមន្ត្រីស៊ីនហ្សូ អាបេ ដើម្បីស្នើសុំការគាំទ្រលើកំណែទម្រង់ការបោះឆ្នោត។ ឆ្លើយតបទៅនឹងការស្នើសុំក្នុងកិច្ចប្រជុំកំពូលនាខែធ្នូ ឆ្នាំ 2013 លោកនាយករដ្ឋមន្ត្រីអាបេបានប្រកាសបញ្ជូនក្រុមអង្កេតរបស់អង្គការJICA ដើម្បីសិក្សាស្ថានភាព និងកំណត់នូវអ្វីដែលជាតម្រូវការចាំបាច់ដើម្បីគាំទ្រដល់ការធ្វើកំណែទម្រង់ការបោះឆ្នោត។

(2) ដោយផ្អែកលើការសិក្សា នៅក្នុងឆ្នាំ 2014 អង្គការ JICA រកឃើញតម្រូវការនៃជំនួយរបស់ជប៉ុនក្នុងវិស័យទាំងបីខាងក្រោម:

ក. ការចុះឈ្មោះបោះឆ្នោត

- ការពារការចុះឈ្មោះស្ងួន និងខុសទិន្នន័យ។

ខ. ការរាប់សន្លឹកឆ្នោតនិងការគណនាលទ្ធផលដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប)

- បង្ការការបោះឆ្នោតច្រើនដង ការគណនាខុស និងការផ្តល់ព័ត៌មានទាន់ពេលវេលា។

គ. ការអប់រំអ្នកបោះឆ្នោត

- ធ្វើយុទ្ធនាការដើម្បីការយល់ដឹង ឧទាហរណ៍ការដាក់បញ្ចូលព័ត៌មានអំពីការបោះឆ្នោតក្នុងប្រព័ន្ធអប់រំ-ល-។

(3) នៅខែឧសភាឆ្នាំ 2015 រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយជាផ្លូវការពីអ្នកជំនាញអង្គការJICA។ ក្នុងអំឡុងកិច្ចប្រជុំកំពូលនៅខែកក្កដាឆ្នាំ2015 លោកនាយករដ្ឋមន្ត្រីអាបេបានប្រកាសថាប្រទេសជប៉ុននឹងផ្តល់ជំនួយសម្រាប់កំណែទម្រង់ការបោះឆ្នោតតាមរយៈ (1) ការផ្តល់អនុសាសន៍ផ្នែកបច្ចេកទេសដល់គជប (2) ការបញ្ជូនអ្នកជំនាញអង្គការ JICA (3) ការផ្តល់ឧបករណ៍។

(4) ជប៉ុនកំពុងផ្តល់ជំនួយសម្រាប់កំណែទម្រង់ការបោះឆ្នោតដូចខាងក្រោម:
ក. ការផ្តល់អនុសាសន៍ផ្នែកបច្ចេកទេសដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត:
- ការពិគ្រោះយោបល់លើសេចក្តីព្រាងបទប្បញ្ញត្តិសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត
- ការពិគ្រោះយោបល់លើសេចក្តីព្រាងបទប្បញ្ញត្តិសម្រាប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ការអនុវត្ត និងការគ្រប់គ្រងការបោះឆ្នោត។
ខ. ការបញ្ជូនអ្នកជំនាញអង្គការ JICA ដើម្បីគាំទ្រដល់:
- ការផ្តល់អនុសាសន៍ផ្នែកបច្ចេកទេសស្តីពីកំណែទម្រង់ការបោះឆ្នោត
- ការធ្វើយុទ្ធនាការដើម្បីការយល់ដឹង និងសកម្មភាពផ្សព្វផ្សាយផ្សេងៗទៀត
- ការធ្វើផែនការនិងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិជ្ជាសារគមនាគមន៍(ICT)ដើម្បីគ្រប់គ្រងការចុះឈ្មោះអ្នកបោះឆ្នោត។
គ. ការផ្តល់ឧបករណ៍រួមមាន:
- Server កុំព្យូទ័រ និងឧបករណ៍ពាក់ព័ន្ធ (UPS, ប្រព័ន្ធbackup, firewall ជាដើម) ដើម្បីផ្ទុកទិន្នន័យឈ្មោះអ្នកបោះឆ្នោត។